| |
|---|
| តុលាការខេត្ត<br>សៀមរាប-ឧត្តរមានជ័យ<br><u>សាលក្រម</u><br>លេខ ១៥ ខ ចុះថ្ងៃទី ១៤<br>ខែ មីនា ឆ្នាំ ២០០៦<br><u>សំណុំរឿងរដ្ឋប្បវេណី</u><br>លេខ ២៤៤ ចុះថ្ងៃទី ០៧<br>ខែ កក្កដា ឆ្នាំ ២០០៥ |

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### តាងនាមប្រជារាស្ត្រខ្មែរ
### តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តសៀមរាប នាថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៦ ដោយមានសមាសភាព :

**<u>ចៅក្រមជំនុំជំរះ</u>**

លោក [redacted] ប្រធានតុលាការខេត្ត

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្ត

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted] ក្រឡាបញ្ជីតុលាការខេត្ត

សាលក្រមនេះចូលជាស្ថាពរចាប់ពីថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៦ ដោយគ្មានភាគីណាមួយចូលមកប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

សៀមរាប.ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៦

**ចៅក្រមជំនុំជំរះ**

**ហត្ថលេខា និង ត្រា**

[redacted]

ដើម្បីជំនុំជំរះសំណុំរឿងក្តីរដ្ឋប្បវេណីលេខ ២៤៤ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៥ ដែលមានកម្មវត្ថុបណ្តឹង **ប្តឹងទាម<u>ទារសំណង</u>ជាប្រាក់ចំនួន ១១.៤៥០ដុល្លាអាមេរិក** ។

រវាងដើមចោទអ្នកស្រី **ច សគ** អាយុ ៥២ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់ដូរ ទីលំនៅ៧ភូមិសាលាកន្សែង ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ **ឡ ច** (ស) ម្តាយឈ្មោះ **ភ ត** ប្តីឈ្មោះ **ន គ** (ស) មានកូន ០៣នាក់ ។

និង ចុងចម្លើយអ្នកស្រី **ស ចម** អាយុ ៤៥ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់ដូរ ទីលំនៅ៧មណ្ឌល១ ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ **ស ហ** (ស) ម្តាយឈ្មោះ **ស សច** (រ) ប្តីឈ្មោះ **ស ហ** មានកូន ០៥នាក់ ។

### <u>ងរឿងហេតុមានដូចតទៅ</u> :

តាមពាក្យបណ្តឹងចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៥ របស់ដើមចោទបានប្តឹងទាមទារសំណងជាប្រាក់ចំនួន ១១.៤៥០ដុល្លាអាមេរិកពីចុងចម្លើយអ្នកស្រី **ស ចម** ដោយសំអាងហេតុថា កាលពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៤ ចុងចម្លើយបានធ្វើមេតុងទីនមានសមាជិក ៣៣នាក់លេងក្នុងតម្លៃ ១០០ដុល្លាអាមេរិក ហើយខ្លួនម្នាក់ឯងលេងពីរក្បាល ។

នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៤ ចុងចម្លើយបានធ្វើមេតុងទីន មានសមាជិក ២៣នាក់លេងក្នុងតម្លៃ ២០០ដុល្លាអាមេរិក ។

ថា ខ្លួនបានទុកតុងទីនចំនួន ០១ក្បាល គេីបយកចុងក្រោយគេ មានទឹកប្រាក់ចំនួន ៥.៨០០ដុល្លាអាមេរិក តែចុងចម្លើយបានប្រគល់ប្រាក់ឱ្យខ្លួនបានត្រឹមតែ ១.២៥០ដុល្លាអាមេរិកប៉ុណ្ណោះ ។

ចំពោះតុងទីនដែលចាប់ផ្តើមលេងនៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៤ ខ្លួនចាំប្រមូលយកចុងក្រោយដែរ បានប្រាក់សរុបចំនួន ៤.៤០០ដុល្លាអាមេរិក តែប្រាក់ដែលខ្លួនប្រមូលយកចុងក្រោយនេះ ចុងចម្លើយពុំប្រគល់ឱ្យខ្លួនឡើយ ។

## នាពេលសវនាការ

ដើមចោទអ្នកស្រី **ច សត** បានឆ្លើយថា ខ្លួនសុំដកពាក្យបណ្តឹងឈប់ប្តឹងពីចុងចម្លើយវិញរហូត ។

ចុងចម្លើយអ្នកស្រី **ស ធម** បានឆ្លើយថា ខ្លួនយល់ព្រមបញ្ចប់រឿងក្តីក្តាំគ្នាជាមួយដើមចោទចាប់ពីពេលនេះតទៅ ។

## តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា

រឿងក្តីនេះជារឿងកិច្ចសន្យា ហើយនៅពេលនេះដើមចោទសុំដកពាក្យបណ្តឹងឈប់ប្តឹងវិញ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

ហេតុនេះសូមតុលាការពិចារណាសំរេចតាមច្បាប់ ។

-បានស្តាប់ចម្លើយដើមចោទឆ្លើយអោយការណ៍ និង ប្តឹងសុំ

-បានស្តាប់ចុងចម្លើយឆ្លើយដោះសារ

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

## តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

-ដើមចោទសុំដកពាក្យបណ្តឹងឈប់ប្តឹងវិញ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-រឿងក្តីនេះតុលាការនឹងចាត់ការតទៅទៀតពុំបានឡើយ ។

## ហេតុដូច្នេះទិនិច្ឆ័យសេចក្តី

១-សំរេចចំណាយរឿងនេះចេញពីបញ្ជីក្តី តាមការសុំរបស់ដើមចោទ ។

២-សំរេចរឹបអូសប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី ៩០០៛០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ១០០៛០០ រង្វាន់ អ្នកប្រគល់ដីកាកោះ ៦.០០០៛០០ បូករួម ៧.០០០៛០០ ។ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០៛០០ ដែលដើមចោទបានបង់ទុករួចហើយ ។

៣-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់រយៈពេល ០២ខែ គិតចាប់ពីថ្ងៃនេះតទៅ ។

| | |
|---|---|
| ក្រឡាបញ្ជីសវនាការ | ចៅក្រមជំនុំជំរះ |
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| [redacted] | [redacted] |